**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប៊ុលតិច អ៊ិនដាសស្ទ្រីល (ខេមបូឌា) លីមីតធីត**

អាសយដ្ឋានៈ អគារលេខ៩ សួនឧស្សាហកម្មខ្សែនៈ២
ភូមិព្រៃសំព័រ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទលេខៈ ០២៣ ៩០០០៨៦ / ០២៣ ៩០០០៨៧
លេខៈ ០០០៣/២០

ថ្ងៃអង្គារ ទី១២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ត្រូវនឹងថ្ងៃទី០២ ខែមិថុនា ឆ្នាំ ២០២០

# កិច្ចព្រមព្រៀង
## រវាង
## នាយកក្រុមហ៊ុន ប៊ុលតិច អ៊ិនដាសស្ទ្រីល (ខេមបូឌា) លីមីតធីត
## ជាមួយតំណាងសហជីពដើម្បីកម្មករប្រចាំក្រុមហ៊ុន

ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ នៅបន្ទប់ប្រជុំលេខ២ នៃក្រុមហ៊ុន ប៊ុលតិច អ៊ិនដាសស្ទ្រីល (ខេមបូឌា) លីមីតធីត / Burltex Industrial (Cambodia) Limited. មានកិច្ចប្រជុំពិភាក្សា រវាងនាយក-ក្រុមហ៊ុន និង តំណាងសហជិពប្រចាំរោងចក្រ ស្តីពីការព្យួរកិច្ចសន្យាការងារ ដោយមូលហេតុនៅពេលថ្មីៗនេះ ជម្ងឺផ្លូវដង្ហើមធ្ងន់ធ្ងរដែលបណ្តាលមកពី មេរោគខូវីដ-១៩ (COVID-19) បានក្លាយទៅជាបញ្ហាប្រឈមដ៏ធំមួយទៀត ដែលបណ្តាលអោយមានភាពរាំងស្ទះក្នុងការនាំចូលវត្ថុធាតុដើមពីប្រទេសចិន។

ហេតុនេះ ក្រោយពីបានពិភាក្សាគ្នារួចមក ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១- ភាគីទាំងពីរយល់ព្រមព្យួរកិច្ចសន្យាការងារកម្មករ-និយោជិតទាំងអស់ចំនួន ៥៥០នាក់ ស្រីចំនួន ៤០៤នាក់ រយៈពេល០២ខែ គិតចាប់ពី ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២០ ។

២- ក្រុមហ៊ុននឹងធ្វើការជូនដំណឹងទៅរាល់ប្រធានក្រុមទាំងអស់ ករណីវត្ថុធាតុដើមនាំចូលបានក្នុងរយៈពេលព្យួរការងារខាងលើ។ ហើយប្រធានក្រុមទាំងអស់ ត្រូវធ្វើការទំនាក់ទំនងទៅសមាជិកក្នុងក្រុមរបស់ខ្លួន ដើម្បីជូនដំណឹងអោយចូលត្រឡប់មកធ្វើការវិញ។

៣- ភាគីទាំងពីរយល់ព្រមទទួលយក ការផ្តល់ប្រាក់ឧបត្ថមតាមសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ ០៤៥/២០ កប/ស.ណ.ជ.ខ.លក្នុងរយៈពេលព្យួរកិច្ចសន្យាការងារខាងលើនេះ។

៤- ក្នុងករណីបងប្អូនកម្មករ មិនបានត្រឡប់ចូលមកធ្វើការវិញតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តតាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

ស្នាមមេដៃតំណាងសហជីពដើម្បីកម្មករ

ស/គ ចាន់ណា. សាន. ស្រេះ. ចាន់ ស៊ីណាត

នាយកក្រុមហ៊ុន

NG CHUNCHUENROBIN